## Refusing direction



១ ចំណាន៖ វុទ្ធី ទំនេរតាសអី? ជួយលាងចានតិច បានអេ៎?
វុទ្ធី៖ ខ្ញុំរៀងរវល់តិចឥឡូវហ្នឹង។ ចាំតិចបានអេ៎? ទុកហ្នឹងសិនហើយ។
ចំណាន៖ អីចឹង វុទ្ធីជួយលាងផងពេលហើយដៃ។

២ ចំណាន៖ វុទ្ធី ជួយជញ្ជូនអីវ៉ាន់តិចមើល នៅច្រើនអ៉ា។
វុទ្ធី៖ ខ្ញុំទៅអត់កើតអេ៎ បង។ ហៅរតនាទៅបង ក្រែងគេទំនេរ។

៣ រតនា៖ វុទ្ធី ម៉ោនេះតិចមើល។
វុទ្ធី៖ ហៅទៅធ្វើអី? រវល់ធ្វើការ។
រតនា៖ ម៉ោតិចម៉ោ។ តែហៅមានការហើយ។

៤ បងប្រុស៖ ធី អ្នកណាគេទូរស័ព្ទម៉ោអ៉ំ ទៅទទួលតិចមើល។
វុទ្ធី៖ ខ្ញុំរវល់អ៉ា មើលមេរៀន។
បងប្រុស៖ លេសរហូត។ ទៅ ទៅទទួលតិចមើល។
វុទ្ធី៖ អត់/អត់ចង់។

| | |
|---|---|
| ចំណាន, រតនា | male or female Cambodian names |
| វុទ្ធី | male Cambodian name |
| ... តាសអី? | ..., right? |
| អេ៎ | spoken form of ទេ |
| ទុកហ្នឹងសិនហើយ | Leave it [here/there] for while! |
| ហើយដៃ = រួចដៃ | [when] free from work, [when] the work is done, lit.: hands free |
| អ៉ា | here: spoken form of ណាស់ |
| អត់កើត | unable, impossible, cannot |
| ក្រែង | maybe |
| ម៉ោ | spoken form of មក |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

| | |
|---|---|
| តែហៅមានការហើយ | I wouldn't call you without a reason |
| ធី | short form of names ending in ធី such as វុទ្ធី |
| អ្នកណាគេទូរស័ព្ទម៉ោអំ | The phone is ringing, you know? |
| លេសរហូត | Always excuses! |

## Cultural notes

គេប្រើពាក្យថា "ប្រើបាន" សំដៅលើក្មេងឬមនុស្សអាយុតិចជាងដែលងាយបង្គាប់ឲ្យធ្វើអ្វីផ្សេងៗ។ ពាក្យផ្ទុយពីនោះ គឺ "ប្រើមិនបាន"។ ក្នុងន័យដូចគ្នា ពាក្យគួរសមនៅពេលសំដៅលើមនុស្សធំឬចាស់ជាងណាដែលចូលចិត្តជួយអ្នកដទៃនៅពេលមានការពឹងពាក់ គឺពាក្យថា "ពឹងបាន"។

| | |
|---|---|
| ប្រើបាន | to be willing to do as ordered |
| បង្គាប់ | to (give an) order, to command |
| អ្នកដទៃ | others |
| ពឹងបាន | to be willing to help |

## Additional dialogue

ម្ដាយ៖ កូន កូនឯងទៅផ្សារទិញបាយ ១០០០ ម៉ោ។
កូន៖ ទិញធ្វើអីម៉ែ? បាយនៅសល់ក្នុងឆ្នាំងតាស!
ម្ដាយ៖ ថាឲ្យទៅទិញ ទៅទិញម៉ោ។
កូន៖ ខ្ញុំទៅម៉េចបានម៉ែ? ខ្ញុំមើលទូរទស្សន៍ចប់សិន។
ម្ដាយ៖ អាឡែងតែមើលទូរទស្សន៍នៅហ្នឹងហើយ។ ប្រើមិនបានម៉ង។

| | |
|---|---|
| ១០០០ = ១០០០ រៀល | 1000 riel; here this means [to buy] cooked rice for 1000 riel |
| ទិញ ... ម៉ោ | buy ... and bring it here |
| ថាឲ្យទៅទិញ ទៅទិញម៉ោ | I told you to go, so just go! |
| អាឡែងតែ | spoken form of រវល់តែ = to be busy with |
| ម៉ង | spoken form of តែម្ដង = totally, at all |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.